01178086

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

D120/2/1/4

**តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៥)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម ន័យ ថុល**
**ចៅក្រម** Kang Jin BAIK
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 12 / 2015
ម៉ោង (Time/Heure): 13:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ:**

**សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត Harmon លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ**

**សហព្រះរាជអាជ្ញា:**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍:**
អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី:**
ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
François GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទទួល "បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត Harmon លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ" ("ម្ចាស់បណ្តឹងឧទ្ធរណ៍" និង "បណ្តឹងឧទ្ធរណ៍") ដែលបានដាក់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥[1]។

1. នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ កិច្ចស៊ើបសួរលើសំណុំរឿង ០០៣ ត្រូវបានផ្តួចផ្តើមឡើងផ្អែកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី២០ ខែវិច្ឆិកាឆ្នាំ២០០៨ ទាក់ទងទៅនឹងនឹងកងទ័ពបដិវត្តន៍កម្ពុជា[2]។ ដីកានេះត្រូវបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង។

2. នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[3]។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[4]។

3. នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានកោះហៅម្ចាស់បណ្តឹងឧទ្ធរណ៍ឱ្យបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤[5]។ ក្រោយពេលម្ចាស់បណ្តឹងឧទ្ធរណ៍បានបដិសេធមិនចូលបង្ហាញខ្លួនលើកដំបូង និងក្រោយពេលនគរបាលយុត្តិធម៌ខកខានមិនបានធានាវត្តមានចូលរួមរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍, ស.ច.ស.អ បានដាក់ម្ចាស់បណ្តឹង

---

[1] សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត Harmon លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ ឯកសារ D120/2/1/2។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ D120។

[4] ញត្តិរបស់លោក មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D120/1។

[5] ដីកាកោះ មាស មុត ឱ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ A66។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRÉLIMINAIRE

ឧទ្ធរណ៍ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[6]។

4. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៥ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ("អ.ប.ជ") នូវបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ស.ច.ស ចំពោះញត្តិរបស់គាត់សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ ស.ព .អ[7]។ ក្រោយពេលទទួលស្គាល់ការផ្លាស់ប្ដូរឋានៈរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្លាយមកជាជនត្រូវចោទ ស.ច.ស.អ បានជូនដំណឹងនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ថា សេចក្ដីសន្និដ្ឋានមុនៗរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍កំពុងស្ថិតក្រោមការពិចារណានៅពេលនេះ[8]។

5. នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ អ.ប.ជ បានចេញសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ស.ច.ស ចំពោះញត្តិរបស់គាត់សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ ស.ព .អ ដោយបានលើកឡើង*នៅក្នុងចំណោមចំណុចទានា*ថា ពេលវេលាដែលត្រូវបានធ្វើចំណាត់ការដោយ ស.ច.ស ពុំចាត់ទុកជាការបដិសេធតាមការសន្មតលើសំណើសុំលុបចោលនោះទេ ហើយក៏បានសម្រេចថា បណ្ដឹងឧទ្ធរណ៍នោះមិនអាចទទួលយកបានតាមទម្រង់ច្បាប់[9]។

---

[6] ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128។

[7] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងទៅនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតចំពោះញត្តិរបស់គាត់សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D120/1/1/1។

[8] ការឆ្លើយតបទៅនឹងសំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចលើសំណើទាំងឡាយរបស់គាត់ដែលបានដាក់នាពេលកន្លងមក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ D132/1។

[9] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D120/1/1/2។

6. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ព្រះបាទសម្តេចព្រះបរមនាថនរោត្តមសីហមុនីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានឡាយព្រះហស្ថលេខាជាកិច្ចការប្រញាប់លើលិខិតតែងតាំងចៅក្រម Bohlander ជា ស.ច.អ នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត។ ចៅក្រម Bohlander និងចៅក្រម Harmon ត្រូវបានជូនដំណឹងជាផ្លូវការអំពីលិខិតតែងតាំងនេះនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥។

7. នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៥ ចៅក្រម Harmon បានចេញដីកាសម្រេចលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[10]។

8. នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[11]។ ក្រោយពីបានដាក់សំណើសុំ អ.ប.ជ អនុញ្ញាតឱ្យខ្លួនដាក់បណ្តឹងឧទ្ធរណ៍នេះជាភាសាអង់គ្លេសជាមុនសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[12] បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ ហើយសំណៅបកប្រែជាភាសាខ្មែរបានដាក់ជូនតាមក្រោយ[13]។

9. នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលសារអេឡិចត្រូនិចមួយច្បាប់ពី Filippo de Minicis ដែលជាមន្ត្រីច្បាប់នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត។ សារអេ

[10] ដីកាសម្រេចលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ D120/2។

[11] សេចក្តីជូនដំណឹងរបស់ មាស មុត អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចសម្រេចលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ឯកសារ D120/2/1។

[12] សំណើរបស់ មាស មុត សុំដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចសម្រេចរបស់សហចៅក្រមស៊ើបអង្កេត Harmon លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិជាភាសាអង់គ្លេសសិន ដោយដាក់ការបកប្រែជាភាសាខ្មែរជូនតាមក្រោយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ D120/2/1/1។

[13] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត Harmon លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ ឯកសារ D120/2/1/2។

ស៊ើបសួរបន្ថែមរបស់ ស.ព.អ[18] ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍នេះត្រូវបានច្រានចោលចាត់ទុកជាអសាបង់ដោយពុំចាំបាច់ត្រូវសម្រេចលើភាពអាចទទួលយកបាន ឬ អង្គសេចក្តីនោះទេ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បដិសេធចោល**បណ្តឹងឧទ្ធរណ៍នេះចាត់ទុកជាអសារបង់។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន** **Olivier BEAUVALLET** **ន័យ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**

---

[18] ដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D120/3។